ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន ស៊ីនឡាន (ខេមបូឌា) ហ្គាមេន ខមេតនី លីមីធីត

XINLAN (CAMBODIA) GARMENT COMPANY LIMITED

អាសយដ្ឋាន ភូមិ ព្រៃបឹង សង្កាត់ កន្ទោក ខណ្ឌ កំបូល រាជធានីភ្នំពេញ

# កិច្ចព្រមព្រៀង

# ក្នុងការកំណត់ផ្តល់ និងបើកប្រាក់ឧបត្ថម្ភ

យើងខ្ញុំទាំងអស់គ្នាជាប្រតិភូពេញសិទ្ធ(ដែលជាអ្នកតំណាងកម្មករនិយោជិត) ប្រចាំក្រុមហ៊ុន ស៊ីនឡាន (ខេមបូឌា) ហ្គាមេន ខមភេនី លីមីធីត។ បានជួបប្រជុំពិភាក្សាគ្នាជាមួយនិងកម្មករនិយោជិតទាំងអស់យ៉ាងយកចិត្តទុកដាក់អំពី ផលលំបាករបស់ក្រុមហ៊ុនដោយ ខ្វះការបញ្ជាទិញទំនិញនិងបញ្ហាសេដ្ឋកិច្ចសកល។ ដូច្នេះ ដើម្បីសម្រួលដល់ចរន្តសេដ្ឋកិច្ចរបស់ក្រុមហ៊ុនឲ្យមានភាពល្អប្រសើរឡើងយើងទាំងអស់គ្នាដែលជាប្រតិភូបុគ្គលិក និង បងប្អូនកម្មករនិយោជិតទាំងអស់បានព្រមព្រៀង និងឯកភាពគ្នាព្យួរកិច្ចសន្យាការងារចំនួន ៣១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣។

បញ្ជាក់ : ការស្នើសុំព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតមានចំនួន ៣៥ នាក់ (ស្រី ៣០ នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៣២២ នាក់ (ស្រី ២៥៩ នាក់)។ ដោយក្រុមហ៊ុនផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ ដុល្លាអាមេរិកយោងតាមប្រកាសលេខ ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ដោយបើកតាមរយៈផ្ទាស់ដៃជូនកម្មករនិយោជិតម្នាក់ៗនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។

ក្រែងពុំប្រាកដយើងខ្ញុំសូមចុះហត្ថលេខា ឬផ្តិតស្នាមមេដៃទុកជាភស្តុតាង។

តំណាងកម្មករនិយោជិត

ភ្លាង សុខុម្ភៈ

ភ្នំ គឹមស៊ុយ

សាយ ស៊ីនៀ

ឡាំ ស៊ីនួន

តំណាងភាគីក្រុមហ៊ុន

ថ្ងៃ ចន្ទ ៤កើត ខែ ភទ្របទ ឆ្នាំ ថោះ បញ្ចស័ក ពស ២៥៦៧

ត្រូវនឹង ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០២៣

នាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ស៊ីនឡាន (ខេមបូឌា) ហ្គាមេន ខមភេនី លីមីធីត XINLAN (CAMBODIA) GARMENT COMPANY LIMITED KINGDOM OF CAMBODIA